# ជំពូកទី១
# សេចក្តីផ្តើម

Draft

# ជំពូកទី ១
# សេចក្តីផ្តើម

## ១.១ លក្ខណៈទូទៅនៃគម្រោង

ព្រះរាជាណាចក្រកម្ពុជាក្នុងពេលបច្ចុប្បន្នកំពុងតែមានសន្ទុះអភិវឌ្ឍន៍ និងរីកលូតលាស់គ្រប់ហេដ្ឋារចនាសម្ព័ន្ធ និងលើគ្រប់វិស័យយ៉ាងឆាប់រហ័ស ទោះបីជាប្រទេសកម្ពុជារបស់យើងទើបតែបានរួចផុតពីសង្គ្រាមដ៏រ៉ាំរ៉ៃក៏ដោយនេះគឺអាស្រ័យដោយកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងពុះពារគ្រប់ឧបសគ្គពីសំណាក់ប្រមុខរាជរដ្ឋាភិបាល និងគ្រប់ស្ថាប័នក្រោមឱវាទទាំងអស់។

វិស័យដែលមានសក្តានុពលសំខាន់បំផុតនោះគឺវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មដែលបានដើរតួនាទីយ៉ាងសំខាន់រួមចំណែកជួយស្តារ កសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឲ្យរីកចម្រើន និងបូករួមទាំងការចូលវិនិយោគលើគ្រប់ផ្នែកទាំងអស់ គឺទាំងការវិនិយោគផលិតផលទំនិញនាំចេញ ការផលិតថាមពល ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគផ្នែកទេសចរណ៍ក៏ដូចជាវិស័យសំខាន់ៗដ៏ទៃទៀត ដែលជួយជម្រុញការអភិវឌ្ឍ និងជំរុញកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាឲ្យមានសន្ទុះលឿនថែមមួយកម្រិតទៀត។

ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី២ បានផ្តល់អាទិភាពខ្ពស់ដល់ការលើកស្ទួយវិស័យកសិកម្ម ក្នុងចំណោមវិស័យសំខាន់ៗដទៃទៀត ក៏ដូចជាច្បាប់វិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់ការអនុគ្រោះ និងលើកទឹកចិត្តយ៉ាងច្រើនសម្រាប់វិស័យនេះក៏ដូចជាវិស័យដទៃៗទៀតដែរដើម្បីទាក់ទាញអ្នកវិនិយោគិនក្នុង និងក្រៅប្រទេសឲ្យចូលមកដាក់ទុនវិនិយោគឲ្យកាន់តែច្រើន ជាពិសេសគោលនយោបាយផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់អ្នកវិនិយោគ គឺដើម្បីវិនិយោគដាំដំណាំកសិ-ឧស្សាហកម្មមានដូចជា : ដើមដូងប្រេង អំពៅ អាកាស្យា ដើមល្ហុងខ្វង និងដើមកៅស៊ូជាដើម។ អាស្រ័យដោយប្រទេសកម្ពុជា មានលក្ខណៈអំណោយផលទៅនឹងអាកាសធាតុ-ភូមិសាស្ត្រ និងមានទីតាំងស្ថិតនៅតំបន់ត្រូពិចដែលសម្បូរដីវាជាតិស្រាប់ដែលមានលក្ខណៈអំណោយផលចំពោះការដាំដំណាំច្រើនមុខ ជាពិសេសដំណាំកសិ-ឧស្សាហកម្មនេះតែម្តង។

តាមរយៈការជំរុញលើកទឹកចិត្តខ្ពស់បែបនេះ និងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋា-ភិបាលក្នុងការលើកស្ទួយវិស័យកសិកម្ម ខេត្តព្រះវិហារក៏មានផែនការ និងគោលដៅដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្តសំដៅធ្វើឲ្យមានកំណើនប្រាក់ចំណូលដល់ប្រជាកសិករបងប្អូនជនជាតិភាគតិច ក៏ដូចជាតាមរយៈការបង្កើនកាលានុវត្តភាពការងារ ការវិនិយោគឯកជន សាធារណៈ និងការពង្រឹងផលិតកម្ម សេវាកម្ម ប្រកបដោយចីរភាព។ គោលដៅចម្បងនេះ គឺផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម ដោយត្រូវបង្កើនទិន្នផលឲ្យបានខ្ពស់ស្តារ និងពង្រីកប្រព័ន្ធធារាសាស្ត្រ ដើម្បីជានាការស្រោចស្រព និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត។

ដោយផ្អែកលើលក្ខណៈអំណោយផលនានា ឱកាសនិងឆ្លើយតបចំពោះតម្រូវការក្នុងការអភិវឌ្ឍប្រទេសជាតិក៏ដូចជាការអភិវឌ្ឍក្នុងតំបន់នៃខេត្តព្រះវិហារ ជាពិសេសដើម្បីចូលរួមចំណែកជួយរាជរដ្ឋាភិបាលសម្រេចបាននូវទិសដៅដែលបានដាក់ចេញ ក្រុមហ៊ុន **ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត (Heng Non (Cambodia) International Company Limited)** បានពិនិត្យឃើញថា ការវិនិយោគទុន ទៅលើគម្រោងបង្កើតកសិដ្ឋានដាំដំណាំកសិ-ឧស្សាហកម្ម ដាំដំណាំអំពៅ និងអាកាស្យាដែលជាការវិនិយោគមួយសមស្របបំផុតនៅលើទឹកដីនៃឃុំតស៊ូ ឃុំពុទ្រា ឃុំស្អាង ស្រុកជ័យសែន ខេត្តព្រះវិហារ នេះដើរស្របជាមួយនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក៏ដូចជាផែនការ និងគោលដៅដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្តផងដែរ។ ម្យ៉ាងទៀត ទីតាំងភូមិសាស្ត្រ

ស្ថានភាពដីនៅទីនោះអំណោយផល និងអនុគ្រោះច្រើនដល់ការដាំដំណាំកសិ-ឧស្សាហកម្ម និងតម្រូវការនៃដំណាំនេះបច្ចុប្បន្នកំពុងតែមានតម្រូវការកើនឡើងជាលំដាប់។

ហេតុនេះ ក្រោយពីបានសិក្សាយ៉ាងល្អិតល្អន់ ព្រមទាំងការផ្ដល់យោបល់ដោយអ្នកជំនាញបច្ចេកទេសជាច្រើនរួចមកក្រុមហ៊ុន បានសម្រេចវិនិយោគលើការដាំអំពៅ និងអាកាស្យា សម្រាប់សេចក្ដីត្រូវការក្នុងប្រទេសក៏ដូចជាការនាំចេញ។

ប៉ុន្តែទោះជាការវិនិយោគនេះ នឹងអាចផ្ដល់នូវគុណប្រយោជន៍ចំពោះការលើកកម្ពស់ការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចខេត្តព្រះវិហារ និងសកម្មភាពសេដ្ឋកិច្ចជាតិក្ដី ក៏ផលជាអវិជ្ជមានជាច្រើននឹងអាចកើតមានឡើងស្របគ្នាផងដែរ ដែលឥទ្ធិពលជាអវិជ្ជមានទាំងនោះ រួមមានការបាត់បង់ធនធានធម្មជាតិនៅក្នុងតំបន់ បន្ទាប់ពីគម្រោងធ្វើការឈូសឆាយ ការបាត់បង់ និងខូចខាតគុណភាពដី និងការបំពុលទឹកជាដើម ដែលតម្រូវឲ្យក្រុមហ៊ុនត្រូវធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ដើម្បីស្វែងយល់អំពីហេតុប៉ះពាល់នានា ព្រមជាមួយនឹងការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់។

ទន្ទឹមនឹងការរីកចម្រើននៃទេសចរណ៍ថ្មី និងការរីកចម្រើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា យើងសង្កេតឃើញថានៅតាមភូមិ-ឃុំ ក៏កំពុងមានការអភិវឌ្ឍន៍គួរឲ្យកត់សម្គាល់ផងដែរ។ តាមរយៈវត្តមានរបស់ក្រុមហ៊ុន Heng Non លើគម្រោងវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម ដំណាំអំពៅនិងអាកាស្យា គឺជាឱកាសដ៏ប្រសើរមួយសម្រាប់ឲ្យប្រជាកសិករនៅខេត្តព្រះវិហារមានការអភិវឌ្ឍន៍កាន់តែប្រសើរជាងមុន ពិសេសគឺវិស័យកសិកម្ម។ ហើយវត្តមានគម្រោងអាចអូសទាញវិស័យផ្សេងៗដូចជា វិស័យឧស្សាហកម្ម(ការផលិតស្ករស) វិស័យដឹកជញ្ជូន វិស័យកសិកម្ម និងវិស័យផ្សេងៗទៀត ដែលជំរុញឲ្យសេដ្ឋកិច្ចក្នុងសហគមន៍ឲ្យមានភាពរីកចម្រើនខ្លាំងឡើង ព្រមទាំងចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រទេសកម្ពុជា។

Draft

## ១.២ គោលបំណងនៃការសិក្សា

គោលបំណងនៃការសិក្សាគម្រោងវិនិយោគដីសម្បទានរបស់ក្រុមហ៊ុន **ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត (Heng Non (Cambodia) International Company Limited)** គឺចង់បង្ហាញពីគោលនយោបាយនៃការអភិវឌ្ឍប្រទេសកម្ពុជាឲ្យមានចីរភាព ពីព្រោះក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលនៃការអភិវឌ្ឍ ជាពិសេសការប្រកួតប្រជែងនៅលើទីផ្សារសេរីក្នុងតំបន់ និងការធ្វើសកលភាវូបនីយកម្ម។

ការសិក្សានេះ ធ្វើឡើងក្នុងគោលបំណង ៖

- ធានាការធ្វើវិនិយោគក្នុងរយៈពេលយូរអង្វែង
- យល់ដឹងពីធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់
- វាយតម្លៃលក្ខខណ្ឌសេដ្ឋកិច្ច-សង្គម ដែលមានស្រាប់នៅជុំវិញទីតាំងគម្រោង
- កំណត់សក្ដានុពល និងរកមូលហេតុនៃការប៉ះពាល់ទៅលើធនធានធម្មជាតិ និងសង្គមដោយសារសកម្មភាពនៃការធ្វើវិនិយោគរបស់ក្រុមហ៊ុន
- កំណត់វិធានការពាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលកើតមានឡើងពីសកម្មភាពគម្រោងឲ្យដល់កម្រិតអប្បបរមា
- ដកស្រង់អនុសាសន៍ល្អៗ ពីស្ថាប័នពាក់ព័ន្ធលើវិធានការការពាររយៈពេលខ្លី-វែង និងលទ្ធផល ឬឥទ្ធិពលមិនល្អរបស់គម្រោងដែលបានស្នើសុំ
- ចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយនិរន្តរភាព។

ក្នុងគោលបំណងបន្ទាប់មកទៀត គឺលើការអនុវត្តន៍ច្បាប់ អនុក្រឹត្យ ប្រកាស គោលការណ៍នៃនាំនានារបស់រាជរដ្ឋាភិបាល និងគោរពតាមការណែនាំរបស់មន្ត្រីមានសមត្ថកិច្ច អ្នកដែលពាក់ព័ន្ធនានា និងចង់បង្ហាញពីការចូលរួមរបស់សាធារណៈជនដូចជា សហគមន៍អ្នកប្រើប្រាស់ទឹក សហគមន៍ព្រៃឈើ សហគមន៍ផ្សេងៗទៀត។ល។

Draft